**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
# ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

- *សូមថ្វាយបង្គំសម្ដេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *សម្ដេច ឯកឧត្តម លោកជំទាវ លោក លោកស្រី*
- *បងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ ក្មួយៗ ជានិស្សិត និងសិស្សានុសិស្សទាំងអស់ជាទីស្រឡាញ់ !*

ក្នុងឱកាសដ៏មហោឡារិកនៃការប្រារព្ធ ***ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨*** នេះ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្ដែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំប្រារព្ធទិវា ដ៏មានសារៈសំខាន់នេះ និងសូមថ្លែងនូវសារលិខិត ថ្វាយ និងប្រគេនព្រះថេរានុត្ថេរៈជាទីសក្ការៈ ជូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ ជាពិសេសក្មួយៗជាយុវជននិស្សិត និងសិស្សានុសិស្សជាទីស្រឡាញ់ទាំងអស់ អំពីបុព្វហេតុ និងឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការបន្តពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាបន្តលើកកម្ពស់ការអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់នូវរាល់អនុសញ្ញា និងពិធីសារអន្តរជាតិនានាដែលកម្ពុជាក្នុងនាមជាសមាជិក ដើម្បីជាឧត្តមប្រយោជន៍រួមរបស់យើងទាំងអស់គ្នា ។

ការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រាប់ឆ្នាំនេះ ត្រូវបានធ្វើឡើងក្នុងពេលដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងបន្តអនុវត្តនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដំណាក់កាលទី៣ ជាបន្តទៀត ដូច្នេះដើម្បីឱ្យយុទ្ធនាការនេះ កាន់តែមានការចូលរួម និងគាំទ្រផុលផុសថែមទៀត ក៏ដូចជាដើម្បីអបអរសាទរការប្រារព្ធ ទិវាអន្តរជាតិនេះ ខ្ញុំសូមបន្តជំរុញឱ្យប្រើប្រាស់ពាក្យស្លោក " ***ចូលរួមទាំងអស់គ្នា ដើម្បីជីវិត និងសហគមន៍យើងគ្មានគ្រឿងញៀន*** " ព្រោះថា មានតែការចូលរួមពីគ្រប់មជ្ឈដ្ឋាននៃសង្គមទេ ទើបបញ្ហាគ្រឿងញៀនអាចដោះស្រាយបានដោយជោគជ័យ ។ សារៈសំខាន់នៃ "ការ**ចូលរួមទាំងអស់គ្នា**" គឺមានន័យថា ត្រូវមានការចូលរួមចាប់តាំងពីបុគ្គលម្នាក់ៗ ក្រុមគ្រួសារនីមួយៗ សហគមន៍ រហូតដល់អង្គភាព ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ហើយធ្វើការព្រមៗគ្នាទៅតាមតួនាទី និងភារកិច្ចពាក់ព័ន្ធទាំងដោយផ្ទាល់ និងដោយប្រយោល ។ ក្នុងនោះ អង្គភាព ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ យកចិត្តទុកដាក់អនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ និងជាប់ជាប្រចាំដោយប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌ វិជ្ជាជីវៈ រីឯក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរ និងសមត្ថកិច្ចនៅតាមមូលដ្ឋាន វិស័យសាសនា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋនៅតាមសហគមន៍ យកចិត្តទុកដាក់ និងលើកកម្ពស់ការអនុវត្តការងារ ផ្សព្វផ្សាយអប់រំ ការងារព្យាបាល ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ ក៏ដូចជាការងារសមាហរណកម្ម អ្នកជាសះស្បើយពីភាពញៀនគ្រឿងញៀនទៅក្នុង គ្រួសារ និងសហគមន៍វិញ ។ កន្លងមកនេះយើងមិនត្រឹមតែបានធ្វើឱ្យមានការថយចុះគួរឱ្យកត់សម្គាល់នូវរាល់បទល្មើស ដែលពាក់ព័ន្ធនឹងគ្រឿងញៀនប៉ុណ្ណោះទេ ប៉ុន្តែ

ថែមទាំងបានធ្វើឱ្យមានការថយចុះនូវបទល្មើសផ្សេងៗទៀតនៅក្នុងសង្គមផងដែរ ដែលលទ្ធផលទាំងនេះ ពិតជាបានរួមចំណែកយ៉ាងសំខាន់ ក្នុងការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលជាកត្តាដ៏សំខាន់ និងមិនអាចខ្វះបានសម្រាប់បង្កលក្ខណៈងាយស្រួលដល់រាជរដ្ឋាភិបាល ក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ ។ ទាំងនេះ គឺជាអ្វីដែលរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុក ដាក់នាពេលកន្លងមក ទាំងសម្រាប់សុខុមាលភាពប្រជាជនផ្ទាល់ ក៏ដូចជាសន្តិសុខសណ្តាប់ធ្នាប់សង្គម ហើយរាជរដ្ឋាភិបាលដែលនឹងបន្តដឹកនាំដោយគណៈបក្សប្រជាជននាពេលខាងមុខ ក៏នឹងនៅបន្តផ្តោតការយកចិត្តទុកដាក់លើការងារនេះ ដោយចាត់ទុកជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពមួយចំនួនទៀតរបស់រាជរដ្ឋាភិបាល ។

ឆ្លៀតក្នុងឱកាសនេះ ទូលបង្គំខ្ញុំព្រះករុណាខ្ញុំសូមកោតសរសើរដោយស្មោះចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួង ស្ថាប័ន អង្គភាព ជាសមាជិក និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ព្រមទាំងកងកម្លាំងអនុវត្តន៍ច្បាប់គ្រប់ប្រភេទ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ អនុវត្តនូវរាល់គោលនយោបាយ វិធានការ និងផែនការនានា របស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងពេលកន្លងមក។ ជាមួយនេះ ខ្ញុំក៏សូមថ្លែងនូវការអរគុណ និងអរព្រះគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ រួមមាន៖ សម្តេចព្រះសង្ឃរាជ និងព្រះតេជគុណគ្រប់ ព្រះអង្គ ក៏ដូចជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក នៃស្ថាប័នព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា វិស័យសាសនា វិស័យឯកជន អង្គការជាតិ-អន្តរជាតិជាដៃគូ ពិសេសបងប្អូនជនរួមជាតិ ដែលបានចូលរួមនិងគាំទ្រយ៉ាងសកម្មផុលផុសនាពេលកន្លងមក។

***សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !***
***សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនជនរួមជាតិជាទីស្រឡាញ់ !***

បើទោះបីជាយើងបានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងដោះស្រាយបញ្ហាគ្រឿងញៀន រហូតទទួលបានលទ្ធផលជាច្រើនគួរជាទីមោទនៈយ៉ាងណាក៏ដោយ ក៏ប៉ុន្តែដោយសារនិន្នាការថ្មីៗនៃបញ្ហាគ្រឿងញៀននៅលើពិភពលោក និងនៅក្នុងតំបន់ ក៏ដូចជាដោយសារស្ថានភាពភូមិសាស្ត្ររបស់ប្រទេសយើងនៅជិតតំបន់ត្រីកោណមាស និងអឌ្ឍច័ន្ទមាសផងនោះ ធ្វើឱ្យក្រុមឧក្រិដ្ឋជន និងបណ្តាញរបស់ពួកវានៅតែបន្តព្យាយាមលួចលាក់ចរាចរឆ្លងកាត់ និងចូលមកកម្ពុជានូវគ្រឿងញៀនខុសច្បាប់ និងសារធាតុប៉ះពាល់ប្រព័ន្ធប្រសាទ ប្រភេទថ្មី ហើយបន្តបង្កផលប៉ះពាល់ទៅលើសុខុមាលភាព និងជីវភាពរស់នៅដ៏សុខក្សេមក្សាន្តរបស់បងប្អូនប្រជាពលរដ្ឋ ក៏ដូចជាប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍសង្គមជាតិរបស់យើង ។ ឆ្លើយតបទៅនឹងបញ្ហាទាំងនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បន្ថែមលើគោលនយោបាយភូមិឃុំមានសុវត្ថិភាព បទបញ្ជាលេខ ០១ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផែនការពហុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដំណាក់កាលទី១ ទី២ ហើយក្នុង ឆ្នាំ២០១៨ នេះ បានបន្តឱ្យអនុវត្តសម្រាប់ដំណាក់កាលទី៣ ជាបន្តទៀត ដោយសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន រួមមានដូចជា៖ បានធ្វើការផ្សព្វផ្សាយ អប់រំឱ្យមានការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋបានចំនួន ១.៦៣៨.៤៩៤ នាក់ បានផ្តល់ការព្យាបាល និងស្តារនីតិសម្បទា ដល់អ្នកញៀនគ្រឿងញៀនបានចំនួន ៧.០៥៦ នាក់ បានបង្ក្រាបបទល្មើសបានចំនួន ២.៨៧០ ករណី និងបានឃាត់ ខ្លួនជនសង្ស័យបានចំនួន ៥.៧០២ នាក់។ ជាមួយគ្នានោះ យើងក៏បានពង្រឹង និងបង្កើតយន្តការចាំបាច់មួយចំនួន បន្ថែមទៀត ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាពនៃការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមមានដូចជា៖ លេខាធិការដ្ឋាន នៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ គណៈកម្មការចម្រុះចំនួន ៦ អនុគណៈកម្មការចម្រុះចំនួន ៣ និង យន្តការសម្រាប់គ្រប់គ្រង និងចាត់ចែងមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន មូលនិធិសង្គ្រោះ និងស្តារ នីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ល។

ក្នុងគោលបំណងថែរក្សាសមិទ្ធផលដែលយើងសម្រេចបានទាំងនេះ ក៏ដូចជាដើម្បីបន្តលើកទឹកចិត្ត និង ជំរុញការចូលរួមនិងគាំទ្របន្ថែមទៀត ពិសេសដើម្បីឈានទៅសម្រេចឱ្យបាននូវគោលបំណងរបស់រាជរដ្ឋាភិបាល ដែលតែងគិតគូរពីសុខុមាលភាព និងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ក៏ដូចជាថែរក្សា ការពារសន្តិសុខ និងសណ្តាប់ធ្នាប់ សាធារណៈ សម្រាប់ការកសាង និងអភិវឌ្ឍប្រទេសជាតិជាបន្តទៀត ពិសេសដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ បន្ថែមទៀតនោះ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមធ្វើការអំពាវនាវ និងសូមធ្វើការណែនាំដូចតទៅ៖

**ទី១**. សូមប្រជាពលរដ្ឋទាំងអស់បន្តស្វែងយល់ឱ្យបានច្បាស់អំពីបញ្ហាគ្រឿងញៀន និងត្រូវចាត់ទុកថា បញ្ហាគ្រឿងញៀនគឺជាបញ្ហារបស់យើងទាំងអស់គ្នា ដោយត្រូវយល់ថា ក្នុងពេលដែលក្រុមគ្រួសារអ្នកដទៃកំពុងប្រឈមជាមួយនឹងបញ្ហានេះ ក្រុមគ្រួសាររបស់យើងក៏អាចបាន និងកំពុងជួបប្រទះនឹងបញ្ហាដូចគ្នានេះដែរ ។ ដូច្នេះសូមបន្តចូលរួមគាំទ្រដល់ក្រុមគ្រួសារជនរងគ្រោះ ព្រមទាំងគាំទ្រនិងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដើម្បីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធអាចចាត់វិធានការអន្តរាគមន៍នានា បានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។ ជាមួយនេះ សូមបន្តពង្រឹងការទទួលខុសត្រូវថែមទៀតក្នុងការអប់រំ និងថែទាំកូនចៅ ឱ្យបានល្អ ដើម្បីបង្ការពួកគេឱ្យចៀសផុតពីបញ្ហាគ្រឿងញៀន ។ ក្នុងករណីសង្ស័យ ឬបានដឹងថា កូនចៅរបស់ខ្លួនមានការពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ត្រូវណែនាំឱ្យបញ្ឈប់ជាបន្ទាន់ ដើម្បីចៀសផុតពីគ្រោះថ្នាក់ផ្នែកសុខភាព និងការផ្តន្ទាទោសតាមផ្លូវច្បាប់ ។ ដោយឡែក ចំពោះកូនចៅដែលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន ត្រូវណែនាំឱ្យបញ្ឈប់ការប្រើប្រាស់ និងលើកទឹកចិត្តឱ្យទៅព្យាបាល ដោយមិនត្រូវលើកហេតុផលផ្សេងៗ ដើម្បីធ្វើជាលេសក្នុងការលាក់ទុក ឬរក្សាទុក មិនបញ្ជូនទៅព្យាបាល ដែលជាការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង និងសហគមន៍នោះឡើយ ។

**ទី២**. ការរៀបចំយន្តការ និងការកសាងជនបង្គោលនៅតាមក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថាន របស់រដ្ឋ និងឯកជន ពិសេសនៅតាមគ្រឹះស្ថានអប់រំសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ ដើម្បីធ្វើការអប់រំ និងណែនាំដល់មន្ត្រី បុគ្គលិក និយោជិក សិស្សានុសិស្ស និងនិស្សិត ឱ្យយល់ដឹងច្បាស់ និងចូលរួមកាន់តែសកម្មថែមទៀតក្នុងការបង្ការ និងទប់ស្កាត់រាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន និងជួយគាំទ្រ ជំរុញឱ្យអ្នកប្រើគ្រឿងញៀនទៅទទួលយកសេវាព្យាបាល ទាំងនៅក្នុងមណ្ឌលបណ្តោះអាសន្ន និងសេវាព្យាបាលដោយ ផ្អែកលើសហគមន៍ នៅតែជាកិច្ចការសំខាន់មួយដែលក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថាន ទាំងអស់ត្រូវយកចិត្តទុកដាក់ និងចាត់ចែងអនុវត្តឱ្យបាន ។

**ទី៣**. ដើម្បីឱ្យការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល កាន់តែទទួលបានលទ្ធផលល្អប្រសើរគ្រប់ក្រសួង-ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ត្រូវបន្តយកចិត្តទុកដាក់និងទទួលខុសត្រូវនៅលើដែនសមត្ថកិច្ចរបស់ខ្លួនបន្ថែមទៀត ទាំងលើការងារពង្រឹងយន្តការក៏ដូចជាការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព បទបញ្ជាលេខ០១ ស្តីពីវិធានការពង្រឹងការងារត្រួតពិនិត្យគ្រឿងញៀនទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន ។ ជាមួយនេះ អាជ្ញាធរ និងសមត្ថកិច្ចមូលដ្ឋាន ត្រូវបង្កើនការយកចិត្តទុកដាក់ឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនូវរាល់សំណូមពរ និងការរាយការណ៍របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនដោយមិនត្រូវរង់ចាំកិច្ចអន្តរាគមន៍ ពីសមត្ថកិច្ចខាងក្រៅ ឬការណែនាំពីថ្នាក់លើនោះហើយ ។ ជាមួយនេះ ត្រូវធ្វើការគាំទ្រដល់ក្រុមគ្រួសារអ្នកញៀន ដើម្បី ឱ្យអ្នកញៀនបានទៅទទួលសេវាព្យាបាលនៅក្នុងសហគមន៍ដោយជាប់លាប់ ។ ទន្ទឹមនោះ ត្រូវពង្រឹងយន្តការគណៈកម្មការត្រួតពិនិត្យគ្រឿងញៀន ឃុំ សង្កាត់ ដើម្បីគាំទ្រដល់ការព្យាបាលដោយផ្អែកលើសហគមន៍។

ត្រូវចាត់ទុកថា បញ្ហាគ្រឿងញៀន ជាបញ្ហាអាទិភាពមួយក្នុងចំណោម បញ្ហាអាទិភាពនានានៅក្នុងមូលដ្ឋានរបស់ខ្លួនដែលត្រូវធ្វើការដោះស្រាយ ។

**ទី៤**. គណៈកម្មការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនលើកទី៣ ត្រូវបន្តដឹកនាំ និងជំរុញការអនុវត្តផែនការសកម្មភាពយុទ្ធនាការឱ្យបានសកម្ម និងខ្លាំងក្លាថែមទៀត ពិសេសផែនការសកម្មភាពរបស់គណៈកម្មការទាំង៦នៃយុទ្ធនាការ ។ ជាមួយនេះ ត្រូវជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត យកចិត្តទុកដាក់បន្ថែមទៀតក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបឱ្យបាននូវរាល់បញ្ហា ដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន ។

**ទី៥**. គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវបន្តពង្រឹង និងពង្រីកសេវាព្យាបាល និងស្តារនីតិសម្បទាឱ្យបានកាន់តែទូលំទូលាយ ដោយត្រូវធ្វើការពង្រឹង សមត្ថភាពមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពបន្ថែមទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាព នៃការផ្តល់សេវាទាំងនៅតាមសហគមន៍ តាមមណ្ឌលបណ្តោះអាសន្ន និងនៅតាមពន្ធនាគារ ធ្វើយ៉ាងណា ឱ្យពួកគេបានជាសះស្បើយទាំងផ្លូវកាយ និងផ្លូវចិត្ត មានបំណិនជីវិត និងជំនាញគ្រប់គ្រាន់ក្នុងការបង្ការការលោប់ទៅប្រើគ្រឿងញៀនឡើងវិញ ក៏ដូចជាមានលទ្ធភាពក្នុងការប្រកបរបរចិញ្ចឹមជីវិតខ្លួនឯង និងគ្រួសារ ។ ក្រសួងសុខាភិបាលត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីដាក់បញ្ចូលអ្នកញៀនគ្រឿងញៀនឱ្យទទួលបានមូលនិធិសមធម៌សម្រាប់ការព្យាបាលដោយមិនគិតប្រាក់ស្របតាមខ្លឹមសារនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជាមួយនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវខិតខំពង្រឹងការងារស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកញៀនគ្រឿងញៀនទៅក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព។

**ទី៦**. ស្ថានីយវិទ្យុ ទូរទស្សន៍ និយ័តករទូរគមនាគមន៍កម្ពុជា ប្រព័ន្ធផ្សព្វផ្សាយនានា សិល្បករ សិល្បការិនី ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ក្លឹបកម្សាន្ត ក្រុមហ៊ុន រោងចក្រ សហគ្រាស ។ល។ សូមបន្តចូលរួមជួយធ្វើសកម្មភាពផ្សព្វផ្សាយបញ្ជូនសារអប់រំស្តីពីបញ្ហាគ្រឿងញៀនឱ្យបានកាន់តែសកម្មផុលផុសថែមទៀត ដើម្បីឱ្យប្រជាពលរដ្ឋរបស់យើង ពិសេសក្រុមគោលដៅជាយុវជនបានយល់ដឹង ចេះការពារខ្លួន និងចូលរួមចំណែកក្នុងការការពារសហគមន៍ពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន។

**ទី៧**. ខ្ញុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ វិស័យសាសនា វិស័យឯកជន សប្បុរសជននានា និងបណ្តាប្រទេសជាមិត្តទាំងអស់ សូមបន្តចូលរួមគាំទ្រ និងឧបត្ថម្ភដល់ការងារប្រយុទ្ធ ប្រឆាំងគ្រឿងញៀននេះ ដើម្បីកម្ពុជាកាន់តែមានលទ្ធភាព សមត្ថភាព ខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងការចូលរួមចំណែកធ្វើឱ្យអាស៊ាន និងពិភពលោក ចៀសផុតពីការគំរាមកំហែងនៃគ្រឿងញៀន ។

មុននឹងបញ្ចប់ អនុញ្ញាតឱ្យទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ ថ្លែងអំណរព្រះគុណ និងអរគុណជាថ្មីម្តងទៀត ចំពោះសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ ថ្នាក់នៃស្ថាប័នព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូជាតិ-អន្តរជាតិ វិស័យសាសនា វិស័យឯកជន សប្បុរសជន សិល្បករ សិល្បការិនី ពិធីករ ពិធីការិនី ម្ចាស់ជំនួយ និងបណ្តាប្រទេសជាមិត្ត ទាំងអស់ ដែល បានខិតខំប្រឹងប្រែងចូលរួម និងគាំទ្រយ៉ាងសកម្មលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននាពេលកន្លងមក និងសូមឱ្យប្រពៃណីនៃការចូលរួមបន្តស្ថិតនៅ និងកាន់តែសកម្មថែមទៀត ដើម្បីជាឧត្តមប្រយោជន៍រួម គឺការ លើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការពារថែរក្សាបាននូវ សន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការអភិវឌ្ឍន៍ប្រទេសជាតិឱ្យរីកចម្រើនទៅមុខកាន់តែឆាប់រហ័ស។

ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ មានសង្ឃឹមយ៉ាងមុតមាំថា សម្តេចព្រះមហាសង្ឃរាជ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ

សម្តេច ឯកឧត្តម លោកជំទាវ ជនរួមជាតិទាំងអស់ នឹងចូលរួមអនុវត្តតាមខ្លឹមសារទាំងអស់នេះ ប្រកបដោយការទទួលខុសត្រូវនិងកាន់តែសកម្មថែមទៀត ដើម្បីធ្វើឱ្យជីវិត និងសហគមន៍យើងគ្មានគ្រឿងញៀន ។

ជាទីបញ្ចប់ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ និងសូមជូនពរជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ សុក្រ ១០៩កើត ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨

**ហ៊ុន សែន**